00894803

E138/1/10/1/5/8/1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**

**ORIGINAL DOCUMENT/DOCUMENT ORIGINAL**

ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 03 / 2013

ម៉ោង (Time/Heure): 10:40

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម **យ៉ា សុខន**

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម **យូរ ឱត្តារា**

កាលបរិច្ឆេទ: ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចស្តីពីការអនុវត្ត "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ" របស់អង្គជំនុំជម្រះតុលាការកំពូល (E138/1/10/1/5/8)

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ជនជាប់ចោទ**

អៀង ធីរិទ្ធ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

Diane ELLIS

ផាត់ ពៅស៊ាង

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

National Road 4 ,Chaom Chau , Dangkao, Phnom Penh, Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:023 218941 Web: www.eccc.gov.kh

## ១. សេចក្តីផ្តើម

១ កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក”) បានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (ឯកសារលេខ E138/1/10/1/5/7) (“សេចក្តីសម្រេច អ.ជ.ត.ក”)។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក បានបដិសេធចោលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចបង្គាប់ឱ្យដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ ហើយ អ.ជ.ត.ក បានសម្រេចបង្គាប់ឱ្យជនជាប់ចោទ៖

ក. ត្រូវជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ឬមន្ត្រីដែលជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូង មុនពេលផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ជនជាប់ចោទ។

ខ. មិនឱ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ។

គ. ត្រូវទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលត្រូវចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង។

ឃ. ត្រូវបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យផ្នែកសន្តិសុខ ដែលអនុវត្តដោយនគរបាលយុត្តិធម៌រៀងរាល់ខែ ឬជម្រើសផ្សេងមួយទៀត អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចឱ្យជនជាប់ចោទផ្តល់របាយការណ៍ប្រចាំខែដើម្បីបញ្ជាក់អំពីការអនុវត្តតាមវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ។

២ អ.ជ.ត.ក ក៏បានបង្គាប់ឱ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់ជនជាប់ចោទជូនទៅអ្នកអាណាព្យាបាលទូទៅ ដោយភ្ជាប់នូវលក្ខខណ្ឌថា មិនត្រូវប្រើលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណទាំងនេះ ក្នុងគោលបំណងធ្វើដំណើរទៅបរទេស ដោយគ្មានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះនោះទេ ហើយនគរបាលយុត្តិធម៌ ត្រូវរាយការណ៍រៀងរាល់ខែជូនទៅអង្គជំនុំជម្រះ ដើម្បីបញ្ជាក់ថា ជនជាប់ចោទនៅតែស្នាក់នៅអាសយដ្ឋាននេះ និងមិនបានចាកចេញពីប្រទេស និងរាយការណ៍អំពីការគម្រាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ[1]។

[1] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ផ្នែកសម្រេចសេចក្តី។

## ២. ប្រវត្តិនីតិវិធី

៣ កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣ មេធាវីការពារក្តី អៀង ធីរិទ្ធ បានស្នើសុំការបញ្ជាក់បំភ្លឺអំពីការអនុវត្ត និងការបកស្រាយសេចក្តីសម្រេច អ.ជ.ត.ក (E138/1/10/1/5/8) ("សំណើសុំរបស់មេធាវីការពារក្តី")។

៤ នៅក្នុងសំណើសុំនេះ មេធាវីការពារក្តីលើកឡើងថា ព័ត៌មានលម្អិតអំពីរបៀបអនុវត្តរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការ គឺមានភាពចាំបាច់ ដើម្បីចៀសវាងការកំហិតបន្ថែមទៀតចំពោះសិទ្ធិ និងសេរីភាពជាសារវ័ន្តរបស់ជនជាប់ចោទ។ មេធាវីការពារក្តីបានស្នើសុំឲ្យធ្វើការបញ្ជាក់បំភ្លឺអំពីប្រសិទ្ធភាពនៃលក្ខខណ្ឌដែលបានកំណត់ចំពោះជនជាប់ចោទដែល អ.ជ.ត.ក បានបង្គាប់ និងជាពិសេស៖

ក. តើអ្នកណា និងតាមរបៀបណា ដែលជនជាប់ចោទត្រូវបានជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ខ្លួន?

ខ. លក្ខណៈនៃការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រទៀងរាល់ប្រាំមួយខែម្តង អត្តសញ្ញាណ និងតួនាទីរបស់មន្ត្រីដែលត្រូវបានជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីបំពេញការងារត្រួតពិនិត្យនេះ ទីកន្លែងដែលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រនោះត្រូវធ្វើ កាលបរិច្ឆេទ និងពេលវេលា។ ប្រសិនបើមានការជូនដំណឹងដល់ភាគី តើភាគីណាខ្លះនៃកិច្ចដំណើរការនីតិវិធី អាចនឹងទទួលបានរបាយការណ៍ទាំងនេះ។ ព្រមទាំងនីតិវិធីដែលត្រូវយកមកអនុវត្ត ក្នុងករណីមានការរកឃើញថា លក្ខខណ្ឌវេជ្ជសាស្ត្រណាមួយដែលមិនបានរកឃើញក្នុងរយៈពេលកន្លងមក បន្ទាប់ពីមានការត្រួតពិនិត្យវេជ្ជសាស្ត្រលើជនជាប់ចោទ ឬនៅពេលជនជាប់ចោទ អៀង ធីរិទ្ធ ធ្លាក់ខ្លួនឈឺនៅពេលអនាគត ឬត្រូវការការព្យាបាល និងការថែទាំវេជ្ជសាស្ត្រប្រភេទណាមួយបន្ថែមទៀត។

គ. អត្តសញ្ញាណ និងតួនាទីរបស់មន្ត្រីដែលត្រូវជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីបំពេញការត្រួតពិនិត្យសន្តិសុខទាំងនេះ ប្រភេទនៃការត្រួតពិនិត្យសន្តិសុខ ទីកន្លែង កាលបរិច្ឆេទ និងពេលវេលាដែលការត្រួតពិនិត្យសន្តិសុខនោះត្រូវធ្វើ និងអត្តសញ្ញាណរបស់បុគ្គលដែលត្រួតពិនិត្យមើលលើបញ្ហាទាំងនេះ។ មេធាវីការពារក្តីបានលើកឡើងថា ខ្លួនមើលឃើញនូវភាពមិនច្បាស់លាស់ថាតើ អ.ជ.ត.ក ចង់បង្កើតរបបមួយដែលមានការត្រួតពិនិត្យពីរដាច់ដោយឡែកគ្នាដែរទេ ពោលគឺការត្រួតពិនិត្យសន្តិសុខមួយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងមួយទៀតដោយជនជាប់

ចោទតាមរយៈអាណាព្យាបាលគាត់ ឬមួយអង្គជំនុំជម្រះតុលាការកំពូលចង់ឱ្យត្រួតពិនិត្យទាំងអស់រួមគ្នា ដោយបញ្ចូលវាតែមួយទៅក្នុងការត្រួតពិនិត្យសកម្មភាព និងការចងក្រងរបាយការណ៍ប្រចាំខែ។ មេធាវីការពារក្ដីក៏បានចោទប្រកាន់អំពីភាពមិនស៊ីសង្វាក់គ្នាចំពោះវិធានការនានាដែល អ.វ.ត.ក បានដាក់ចេញ និងតួនាទីជាន់គ្នាដែលអាចមាន ដោយពិចារណាទៅលើតួនាទីដូចគ្នារបស់អាជ្ញាធរកម្ពុជា ក្នុងការធានាសុវត្ថិភាពរបស់ជនជាប់ចោទ។

ឃ. នីតិវិធីដែលនឹងត្រូវអនុវត្ត ដើម្បីទទួលបានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលជនជាប់ចោទមានបំណងចង់ចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដោយសារមូលហេតុវេជ្ជសាស្ត្រ ដោយពិចារណាទៅលើស្ថានភាពសុខភាពទ្រុឌទ្រោមរបស់ជនជាប់ចោទ និងភាពប្រថុចប្រញ៉ុចនៃសំណើសុំដែលមានលក្ខណៈបន្ទាន់។

ង. ដោយពិចារណាទៅលើផលប៉ះពាល់មិនល្អដែលអាចមានក្នុងការបំពានណាមួយទៅលើលក្ខខណ្ឌទាំងនេះទៅលើសិទ្ធិរបស់ជនជាប់ចោទ នីតិវិធីដែលអង្គជំនុំជម្រះយកមកអនុវត្ត ត្រូវតែបញ្ជាក់បំភ្លឺអំពីនីតិវិធីដែលត្រូវអនុវត្ត ប្រសិនបើជនជាប់ចោទ មិនអាចបំពេញបានទៅតាមពេលវេលាដែលតុលាការបានកំណត់ ឬរំលោភលើលក្ខខណ្ឌទាំងនេះ ដោយសារតែអសមត្ថភាពផ្នែកផ្លូវកាយ និងផ្លូវចិត្តរបស់គាត់[2]។

៥ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មិនបានឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីការពារក្ដីនេះទេ។

## ៣. សំអាងហេតុ

៦ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាពុំមានមូលដ្ឋានផ្លូវច្បាប់ណាមួយសម្រាប់សំណើសុំបច្ចុប្បន្ននេះទេ។ សេចក្ដីសម្រេចនេះត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូល ដែលមានឆន្ទានុសិទ្ធិ និងអំណាចបញ្ជាក់បំភ្លឺសេចក្ដីសម្រេច ឬដីកាសម្រេចរបស់ខ្លួនបាន។ អនុលោមតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការបង្ហាញមតិយោបល់ ឬ បញ្ជាក់បំភ្លឺលើសេចក្ដីសម្រេចរបស់ អ.វ.ត.ក ឡើយ[3]។

---

[2] សំណើសុំរបស់មេធាវីការពារក្ដី កថាខណ្ឌ៨-២៨។

[3] *សូមមើលបន្ថែម* មាត្រា ៦០៦(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ដែលចែងថា តុលាការត្រូវបកស្រាយសេចក្ដីសម្រេចរបស់ខ្លួន)។

៧ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបញ្ជូនសំណើសុំរបស់ក្រុមមេធាវីការពារក្ដីបន្តទៅឱ្យអង្គជំនុំជម្រះតុលាការកំពូលដើម្បីផ្ដល់ការណែនាំ និងសេចក្ដីបង្គាប់បន្ថែម។ ចំពោះសំណើសុំរបស់ក្រុមមេធាវីការពារក្ដីដែលបានដាក់ជូនមកអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះក៏បានរិះរកវិធានការនានាដែលក្នុងពេលបច្ចុប្បន្ន អង្គជំនុំជម្រះកំពុងពិចារណាអនុវត្តសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ផងដែរ ទន្ទឹមនឹងការរង់ចាំអនុវត្តតាមសេចក្ដីណែនាំបន្ថែមទៀតពី អ.ជ.ត.ក បន្ទាប់ពីមានសំណើសុំឱ្យធ្វើការបញ្ជាក់បំភ្លឺជាក់លាក់មួយចំនួនតូចផ្សេងទៀត។

## ៣.១. វិធានការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តសេចក្ដីសម្រេច អ.ជ.ត.ក

៨ លុះត្រាតែអាចមានការណែនាំបន្ថែមពីអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងប្រមើលមើលថា នឹងអនុវត្តនូវវិធានការនានា ដែលជាការ អនុវត្តសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ដូចខាងក្រោម៖

### ៣.១.១. ការជូនដំណឹងអំពីការផ្លាស់ប្ដូរអាសយដ្ឋាន និង/ឬការធ្វើដំណើរទៅបរទេស

(ក) ជនជាប់ចោទ ឬ អាណាព្យាបាល ត្រូវជូនដំណឹងដល់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលា-ដំបូង យ៉ាងហោចណាស់ឱ្យបាន ០៧(ប្រាំពីរ)ថ្ងៃមុនពេលធ្វើការផ្លាស់ប្ដូរអាសយដ្ឋាន ក៏ដូចជាមុនពេលធ្វើដំណើរទៅបរទេស។ អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ពីការទទួលបានការជូន ដំណឹងពីការផ្លាស់ប្ដូរអសយដ្ឋានជនជាប់ចោទ ឬការយល់ព្រមចំពោះការធ្វើដំណើររបស់ជនជាប់ចោទទៅបរទេស តាមការជាក់ស្ដែងដែលអាចធ្វើបាន។

### ៣.១.២. ការពិនិត្យសុខភាព

(ក) អង្គជំនុំជម្រះសាលាដំបូងនឹងតែងតាំងអ្នកជំនាញវិកលវិទ្យាមួយរូប ដើម្បីធ្វើការវាយតម្លៃឡើងវិញឱ្យបានទៀងទាត់លើមុខងារសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ តាមសេចក្ដីបង្គាប់នៅក្នុងកថាខណ្ឌ ៦៧-៦៨ នៃសេចក្ដីសម្រេចរបស់ អ.ជ.ត.ក។ ព័ត៌មានលម្អិតបន្ថែមពាក់ព័ន្ធនឹងអត្តសញ្ញាណនៃអ្នកជំនាញវិកលវិទ្យា និងរយៈពេលនៃការវាយតម្លៃនៅថ្ងៃដំបូង និងថ្ងៃបន្តបន្ទាប់នឹងត្រូវធ្វើការជូនដំណឹងនៅក្នុងពេលសមស្រប នាពេលក្រោយ។

(ខ) របាយការណ៍ទៀងទាត់ទាំងនេះត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

### ៣.១.៣. របាយការណ៍ស្ដីពីការគោរពតាមលក្ខខណ្ឌនានា

(ក) ប្រសិនបើជនជាប់ចោទ តាមរយៈអាណាព្យាបាលទូទៅរបស់គាត់ ផ្ដល់ការបញ្ជាក់ជារៀងរាល់ខែនៅថ្ងៃចុងក្រោយនៃថ្ងៃធ្វើការក្នុងខែនីមួយៗ (គិតចាប់ពីថ្ងៃ សុក្រ ទី ២៩ ខែ មីនា ឆ្នាំ ២០១៣) ជូនដល់អង្គជំនុំជម្រះសាលាដំបូងថា ខ្លួនកំពុងស្ថិតនៅក្នុងអាសយដ្ឋានបច្ចុប្បន្នរបស់គាត់ និងរាយការណ៍អំពីការគម្រាមកំហែងណាមួយលើសុវត្ថិភាពរបស់គាត់នោះ អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឲ្យជនជាប់ចោទ ឬនគរបាលយុត្តិធម៌ ធ្វើការត្រួតពិនិត្យបញ្ហាសន្តិសុខបន្ថែមណាមួយឡើយ។

### ៣.២. សំណើសុំឲ្យ អ.ជ.ត.ក បញ្ជាក់បំភ្លឺលើសំណើសុំរបស់ក្រុមមេធាវីការពារក្ដី

៩ អង្គជំនុំជម្រះសាលាដំបូងស្នើសុំការណែនាំលើការអនុវត្តសេចក្ដីសម្រេចនៃ អ.ជ.ត.ក ដូចខាងក្រោម៖

### ៣.២.១. ការពិនិត្យសុខភាព

(ក) អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការវាយតម្លៃទៀងទាត់លើបញ្ហាសុខភាពនឹងត្រូវកម្រិតត្រឹមស្ថានភាពសតិបញ្ញាស្មារតីនៃជនជាប់ចោទប៉ុណ្ណោះ។ ក្រោយពីពិចារណាលើពាក្យពេចន៍នៅក្នុងកថាខណ្ឌ ៦៨ នៃសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ពាក់ព័ន្ធនឹង "ស្ថានភាពចុះខ្សោយជាទូទៅ" របស់ជនជាប់ចោទ តើអង្គជំនុំជម្រះតុលាការកំពូលអាចផ្ដល់សេចក្ដីបង្គាប់ថា តើការវាយតម្លៃទៀងទាត់ត្រូវធ្វើឡើងដូចការយល់ឃើញខាងលើនេះដែរ ឬទេ[4]?

(ខ) ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា ឲ្យធ្វើការវាយតម្លៃបន្ថែមទៀតលើបញ្ហាសុខភាពជាទូទៅ តើអង្គជំនុំជម្រះតុលាការកំពូលអាចផ្ដល់ការណែនាំទេថាតើ

---

[4] កថាខណ្ឌ ៦៨ នៃសេចក្ដីសម្រេចរបស់ អ.ជ.ត.ក បានសរសេរដូច្នេះថា "អង្គជំនុំជម្រះទទួលស្គាល់ថា ការវាយតម្លៃផ្នែកផ្លូវចិត្តសម្រាប់ជំងឺបាត់ការចងចាំ និងមុខងារបញ្ញាស្មារតី ដែលច្រើនតែពាក់ព័ន្ធនឹងការធ្វើតេស្តការចងចាំ និងបញ្ហាផ្ទាល់ខ្លួនទូទៅ ប៉ះពាល់ដល់សិទ្ធិឯកជន និងកិត្តិយសផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែរ បើទោះពីជាការវាយតម្លៃនោះមានលក្ខណៈរំខានបន្តិចបន្តួចក៏ដោយ។ យ៉ាងណាមិញ អង្គជំនុំជម្រះពិចារណាឃើញថា នៅដំណាក់កាលនេះ មានការប៉ះពាល់សិទ្ធិតិចតួចបំផុត។ ជនជាប់ចោទ ដោយសារតែលក្ខខណ្ឌរបស់គាត់ទន់ខ្សោយ ត្រូវការការថែទាំផ្នែកវេជ្ជសាស្ត្រ។ យោងទៅតាមលទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្រក្នុងការវិភាគជំងឺ និងអនុសាសន៍នៃការព្យាបាល មានភាពស្របគ្នារវាងប្រយោជន៍របស់ជនជាប់ចោទ និងប្រយោជន៍យុត្តិធម៌ ដែលតម្រូវឲ្យផ្ដល់ព័ត៌មានជាបន្តបន្ទាប់ទាក់ទងនឹងសុខភាពស្មារតីរបស់ជនជាប់ចោទ"។

បុគ្គលណាជាអ្នកទទួលខុសត្រូវលើការចំណាយទៅលើការវាយតម្លៃទាំងនេះ ហើយថាតើការព្យាបាលសុខភាពណាមួយ អាចត្រូវធ្វើឡើងទេ?

***៣.២.២. សេចក្តីណែនាំនៅក្នុងករណីពុំគោរពតាមលក្ខខណ្ឌកំណត់តាមផ្លូវតុលាការ***

(ក) បើទោះជាអង្គជំនុំជម្រះសាលាដំបូងបានខិតខំឱ្យអស់ពីលទ្ធភាពយ៉ាងណាក៏ដោយ ប្រសិនបើជនជាប់ចោទនៅតែបំពានទៅលើលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ តើ អ.ជ.ត.ក អាចបញ្ជាក់បានឬទេថា តើទណ្ឌកម្មសមស្របណាមួយដែលអាចធ្វើឡើងនោះ ហើយតើត្រូវធ្វើឡើងចំពោះបុគ្គលណា (ជនជាប់ចោទខ្លួនឯង និង/ឬ អាណាព្យាបាលទូទៅរបស់គាត់?)

## ៤. សេចក្តីសម្រេច

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**បដិសេធ** សំណើរបស់ក្រុមមេធាវីការពារក្តីសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់បំភ្លឺបន្ថែមពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តសេចក្តីសម្រេចរបស់ អ.ជ.ត.ក។

**បញ្ជូន** សំណើសុំរបស់ក្រុមមេធាវីការពារក្តី រួមជាមួយនឹងសេចក្តីសម្រេចនេះទៅឱ្យអង្គជំនុំជម្រះតុលាការកំពូល ដើម្បីផ្តល់សេចក្តីណែនាំ និងកំណត់អំពីចំណាត់ការបន្ថែមណាមួយដែលអង្គជុំនំជម្រះយល់ឃើញថាសមស្រប។

**ជម្រាបជូន** ដល់អង្គជំនុំជម្រះតុលាការកំពូលអំពីវិធានការខាងលើ ដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថាត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់ អ.ជ.ត.ក ដោយត្រូវអនុវត្តតាមសេចក្តីណែនាំបន្ថែមណាមួយរបស់អង្គជំនុំជម្រះតុលាការកំពូល និង **ស្នើសុំ** ការណែនាំពីអង្គជំនុំជម្រះតុលាការកំពូលលើបញ្ហាខាងលើ ដែលត្រូវបានស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

**និល ណុន**